**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង

**រវាង**

**ក្រុមហ៊ុន ហ្គោថូន ត្រាវែល សឺវីស**

**និង**

**តំណាងកម្មករនិយោជិត**

## ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នាថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០២៤ វេលាម៉ោង ១០ និង ០០នាទី ព្រឹក នៅក្នុងក្រុមហ៊ុន ហ្គោថូន ត្រាវែល សឺវីស មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិត។

នៅក្នុងអង្គប្រជុំ នាយកក្រុមហ៊ុនបានជូនដំណឹងដល់ កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងក្រុមហ៊ុនថា ដោយសារបញ្ហាជំងឺ**កូវីត១៩** (Covid-19) ដែលធ្វើអោយស្ថានភាពពិភពលោកទាំងមូលក៏ដូចជាព្រះរាជាណាចក្រកម្ពុជាយើងជួបនូវវិបត្តិសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ ធ្វើអោយភ្ញៀវទេសចរណ៍ទាំងអស់នៅលើពិភពលោកពុំអាចធ្វើដំណើរចេញក្រៅប្រទេស ធ្វើអោយក្រុមហ៊ុនពុំមានចំណូល ហើយបណ្តាក្រុមហ៊ុនមួយចំនួនធំនៅលើពិភពលោកត្រូវបានបិតទ្វារពុំមានចរាចរណ៍ឡើយ ហេតុដូចនេះក្រុមហ៊ុនបានសំរេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ១៩នាក់ (ស្រី ៦នាក់) ចំនួន០២ខែ ដោយគិតចាប់ពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៤។ ដោយនៅក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះក្រុមហ៊ុនពុំមានលទ្ធភាពក្នុងការផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករនិយោជិកទាំងអស់នោះទេ។

អង្គប្រជុំបានចប់នៅវេលាម៉ោង ១០ និង ៣០នាទី នាថ្ងៃខែឆ្នាំដដែល ដោយភាគីទាំងសងខាងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួល និងសហការគ្នាយ៉ាងរលូន។

សៀមរាប, ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៤

**តំណាងកម្មករន និយោជិត**

**នាយកក្រុមហ៊ុន**

Scanned with ACE Scanner